# ទីស្តីការប្រធានរដ្ឋ

**លេខ ០១ ក.ច**

# ក្រឹត្យ-ច្បាប់

## កំណត់អង្គការចាត់តាំងតុលាការប្រជាជនបដិវត្តគ្រប់ខេត្ត-ក្រុង

## ក្រុមប្រឹក្សាប្រជាជនបដិវត្ត

ផ្អែកលើភារកិច្ចរបស់ក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជា ដែលបានចែងក្នុងសេចក្តីប្រកាសថ្ងៃទី០៨ ខែមករា ឆ្នាំ១៩៧៩

តាមសំណើរបស់លោករដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងលោករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេចចេញក្រឹត្យ-ច្បាប់

**ប្រការ ១** បង្កើតតុលាការប្រជាជនបដិវត្តគ្រប់ខេត្ត-ក្រុង ។

តុលាការប្រជាជនបដិវត្តខេត្ត-ក្រុង មានភារកិច្ចជំនុំជម្រះវិនិច្ឆ័យទោសជនជាប់ទោសក្បត់បដិវត្តន៍ និងបណ្តាជនជាប់ទោសផ្សេងៗទៀត រួមចំណែកក្នុងការការពាររដ្ឋអំណាចបដិវត្តការពាររបៀបរៀបរយសង្គម ការពារទ្រព្យសម្បត្តិសាធារណៈ អាយុជីវិត ទ្រព្យសម្បត្តិ សិទ្ធិ ផលប្រយោជន៍ដ៏ត្រឹមត្រូវសមរម្យនានាផ្សេងៗទៀតរបស់ពលរដ្ឋ ។

ការអនុវត្តន៍ទណ្ឌកម្មចំពោះជនជាប់ទោស គឺមិនត្រឹមតែផ្តន្ទាទោសទេព្រមទាំងមានបំណងអប់រំ កែលំអជនជាប់ទោសអោយប្រែក្លាយជាពលរដ្ឋសុចរិតស្លូតត្រង់វិញ ។

**ប្រការ ២** តុលាការប្រជាជនបដិវត្តខេត្ត-ក្រុង រួមមានចាងហ្វាងតុលាការ ចាងហ្វាងរង និងចៅក្រម ។ ពេលជំនុំជម្រះក្រុមប្រឹក្សាជំនុំជម្រះរួចមានចៅក្រមមួយនាក់ និងសភាប្រជាជនពីរនាក់ ។ ក្នុងករណីចាំបាច់អាចមានចៅក្រមពីរនាក់ និងសភាប្រជាជនបីនាក់ ។

**ប្រការ ៣** ការជំនុំជម្រះនៅតុលាការប្រជាជនបដិវត្តមានសភាប្រជាជនចូករួម ។

សភាប្រជាជន គឺដោយសមាគមប្រជាជនចាត់តាំង ។ ពេលជំនុំជម្រះសភាប្រជាជនមានសិទ្ធិអំណាចស្មើនឹងចៅក្រម ។

**ប្រការ ៤** តុលាការប្រជាជនបដិវត្តជំនុំជម្រះ តាមគោលកាណ៍នេះរាល់រូបមានសិទ្ធិស្មើគ្នាចំពោះមុខតុលាការ មិនប្រកាន់ប្រុស ស្រី ជនជាតិសាសនា ឋានៈសង្គម ។

**ប្រការ ៥** តុលាការប្រជាជនបដិវត្ត អនុវត្ត របបសមូហភាពជំនុំជម្រះហើយសម្រេចតាមភាគច្រើន ។

**ប្រការ ៦** តុលាការប្រជាជនបដិវត្តជំនុំជម្រះជាចំហ លើកលែងតែករណីពិសេសខ្លះដែលឃើញថាគួរតែរក្សាការសម្ងាត់របស់រដ្ឋ ឬ សីលធម៌សង្គម ។

**ប្រការ ៧** សិទ្ធិការពារ របស់ជនជាប់ចោទ ត្រូវបានធានា ។

ជនជាប់ចោទអាចការពារខ្លួនដោយផ្ទាល់ ឬ មានសំណូមពរអោយតុលាការប្រជាជនបដិវត្តចាត់តាំងអ្នកការពារអោយខ្លួន ។

**ប្រការ ៨** សាលក្រម និងសេចក្តីសម្រេចចិត្តរបស់តុលាការប្រជាជនបដិវត្តគឺមានប្រសិទ្ធភាពភ្លាមជាបន្ទាន់ ។

សាលក្រមកាត់ទោសប្រហារជីវិតទាំងអស់ ត្រូវបានសមូហភាពគណៈអចិន្ត្រៃយ៍ក្រុមប្រឹក្សាប្រជាជនបដិវត្តថ្នាក់មជ្ឈិមពិនិត្យយល់ព្រមជាមុនទើបរអនុវត្ត ។

**ប្រការ ៩** សមាជិកអយ្យការ អមតុលាការប្រជាជនបដិវត្តខេត្ត-ក្រុង មានភារកិច្ច និងសិទ្ធិអំណាចដូចតទៅៈ

ក-ចោទប្តឹង ឬ មិនចោទប្តឹង ជនជាប់ចោទទៅតុលាការ ។

ខ-រក្សាសិទ្ធិរបស់ខ្លួននៅអង្គប្រជុំតុលាការ ។

គ-ត្រួតមើលការអនុវត្តន៍ទណ្ឌកម្ម ។

**ប្រការ ១០** ចាងហ្វាងតុលាការ ចាងហ្វាងរង ចៅក្រមរបស់តុលាការប្រជាជនបដិវត្តខេត្ត-ក្រុង និងសមាជិកអយ្យការអមតុលាការប្រជាជនបដិវត្តខេត្ត-ក្រុង គឺដោយក្រុមប្រឹក្សាប្រជាជនបដិវត្តថ្នាក់មជ្ឈិមចាត់តាំងតាមសំណើរបស់គណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុង ។

**ប្រការ ១១** លោករដ្ឋមន្ត្រីក្រសួងយុត្តិធម៌ លោករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងលោកប្រធានគណៈកម្មាធិការប្រជាជនបដិវត្តគ្រប់ខេត្ត-ក្រុង ត្រូវទទួលខុសត្រូវខាងអនុវត្តន៍ក្រឹត្យ-ច្បាប់នេះ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៨០

ជ.ក្រុមប្រឹក្សាប្រជាជនបដិវត្ត

**ប្រធាន**

**ហេង សំរិន**